# រាជបណ្ឌិត្យសភាកម្ពុជា

## វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

# គំនិតផ្តួចផ្តើមផ្លូវនិងខ្សែក្រវាត់ និងការអភិវឌ្ឍសេដ្ឋកិច្ច នៅកម្ពុជា

**ដោយៈ បណ្ឌិត ព្រុំ ទេវី**

ខែឧសភា ឆ្នាំ២០១៩

# គំនិតផ្តួចផ្តើមផ្លូវនិងខ្សែក្រវាត់ និងការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា

បណ្ឌិត ព្រុំ ទេវី
អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
នៃរាជបណ្ឌិត្យសភាកម្ពុជា

កម្ពុជាមានប្រវត្តិសាស្ត្រយូរអង្វែងស្តីអំពីអន្តោប្រវេសន៍ចិនជាសហគ្រិននិងពលករ។ ភស្តុតាងដំបូងបង្អស់នៃវត្តមានរបស់ចិននៅកម្ពុជាគឺតាមកំណត់ហេតុរបស់លោក ជីវ តាក្វាន់ ដែលបានសរសេរនៅសតវត្សរ៍ទី១៣[1]។ នាថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៥៨ ក្រោមការដឹកនាំរបស់ **សម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ** និង **លោកប្រធាន ម៉ៅ សេទុង** ប្រទេសទាំងពីរមានផ្សាភ្ជាប់ទំនាក់ទំនងការទូតជាមួយគ្នារៀងរហូតមក។

ក្នុងស្មារតីបន្តមរតកនៃទំនាក់ទំនងរវាងប្រទេសទាំង សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងថ្នាក់ដឹកនាំចិនជំនាន់ថ្មី បានរួមគ្នាពង្រឹងនិងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការទ្វេភាគីរហូតដល់កម្រិត **ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ** និងក្នុងឋានៈជា**មិត្តដែលទុកចិត្តជាទីបំផុត**។ ម្យ៉ាងកម្ពុជាគាំទ្រចិនយ៉ាងមុតមាំ ទាំងក្នុងកម្រិតតំបន់ ទាំងក្នុងកម្រិតអន្តរជាតិ ដូចក្នុងឆ្នាំ២០១២បានបង្ហាញជាឧទាហរណ៍ស្រាប់។ មិនតែប៉ុណ្ណោះកម្ពុជាបាននិងកំពុងគាំទ្រយ៉ាងពេញទំហឹងនូវគំនិតផ្តួចផ្តើមរបស់ចិនជាច្រើនដូចជាធនាគារវិនិយោគអាស៊ី(AIIB) និងគំនិតផ្តួចផ្តើមផ្លូវមួយ ខ្សែក្រវ៉ាត់មួយ(Belt and Road Initiative: BRI)។ ម្យ៉ាងវិញទៀតចិនបានទទួលស្គាល់និងគាំទ្រជាបន្តបន្ទាប់ដល់កម្ពុជាជាជំនួយឥតសំណងនិងឥណទានជារៀងរាល់ឆ្នាំ។

## គំនិតផ្តួចផ្តើមផ្លូវនិងខ្សែក្រវាត់

គំនិតផ្តួចផ្តើមផ្លូវនិងខ្សែក្រវ៉ាត់បានចាប់ផ្តើមក្នុងឆ្នាំ២០១៣ ដោយរដ្ឋាភិបាលចិន ដើម្បីផ្សាភ្ជាប់ទ្វីបអាស៊ី អឺរ៉ុប និងអាហ្វ្រិក។ គំនិតផ្តួចផ្តើមនេះមានគោលដៅចំនួន៣សំខាន់ៗ (១)លើកកម្ពស់កំណើនសេដ្ឋកិច្ចសកល (២)ធ្វើឱ្យសម្រេចបានតុល្យភាពជាសកល និង(៣)បង្កើតគំរូថ្មីនៃកិច្ចសហប្រតិបត្តិការក្នុងតំបន់នៅក្នុងសតវត្សរ៍ទី២១។ BRIផ្តោតលើកិច្ចសហប្រតិបត្តិ៥វិស័យគឺ (១)កិច្ចសម្របសម្រួលគោលនយោបាយ; (២)ការផ្សាភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត; (៣)ភាពរលូននៃទំនាក់ទំនងពាណិជ្ជកម្ម; (៤)សមាហរណកម្មហិរញ្ញវត្ថុ និង(៥)ការផ្សាភ្ជាប់ប្រជាជននិងប្រជាជន។ មិនតែប៉ុណ្ណោះ BRIព្យាយាមបង្កើតសហគមន៍ចំនួន៥គឺៈ (១)សហគមន៍ដែលមានអរិយធម៌;(២)សហគមន៍មានគោលបំណងរួមគ្នា; (៣)សហគមន៍ចែករំលែកការទទួលខុសត្រូវ; (៤)សហគមន៍មានសុវត្ថិភាព និង(៥)សហគមន៍មានជោគ វាសនារួមគ្នា។ នៅក្នុងវេទិកាផ្លូវនិងខ្សែក្រវ៉ាត់លើកទី១ ប្រធានាធិបតី **ស៊ី ជីនភីង** (XiJinping)

[1] https://km.wikipedia.org/wiki/កំណត់ហេតុ ជីវ តាក្វាន់។ ដកស្រង់ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៩។

បានកំណត់គោលការណ៍គន្លឹះសម្រាប់ BR ចំនួន៥គឺ BR (១) ជាវិថីដើម្បីសន្តិ-ភាព; (២) ជាវិថីដើម្បីភាពរីចម្រើន; (៣) ជាវិថីសម្រាប់ការបើកចំហរ; (៤) ជាវិថីសម្រាប់នវានុវត្តន៍ និង (៥) ជាវិថីផ្សាភ្ជាប់អរិយធម៌[2]។ ៦ឆ្នាំក្រោយការចាប់ផ្ដើម បើសិនជាគេសង្ខេប BRIឱ្យនៅតែជាពាក្យមួយម៉ាត់គឺ *ការផ្សាភ្ជាប់* ប៉ុន្តែជាក់ស្តែងមានទិដ្ឋភាពលើសពីការភ្ជាប់ប្រទេសមួយទៅប្រទេសមួយដោយហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត។

ក្នុងនាមជាមិត្តចាស់និងជាមិត្តភក្តិដែលគួរឱ្យទុកចិត្តបំផុតរបស់ប្រទេសចិន កម្ពុជាទទួលបានអត្ថប្រយោជន៍យ៉ាងច្រើនពីគម្រោងខ្សែក្រវាត់និងផ្លូវ។ ទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរបានកើនឡើងជាបន្តបន្ទាប់។ ក្នុងឆ្នាំ២០១៧ ទំហំពាណិជ្ជកម្មកម្ពុជា-ចិនបានកើនឡើងដល់៥,៨ពាន់លានដុល្លារអាម៉េរិក កើន២២%ធៀបទៅនឹងឆ្នាំ២០១៦។ ក្នុងទសវត្សរ៍ចុងក្រោយនេះ កំណើនប្រចាំឆ្នាំជាមធ្យម២៦%[3]។ ក្នុងឆ្នាំ២០១៩ ប្រទេសទាំងពីរបានព្រមព្រៀងគ្នាបង្កើនទំហំពាណិជ្ជកម្មជាលក្ខណៈទ្វេភាគីឱ្យបានរហូតដល់១០ពាន់លានដុល្លារអាម៉េរិកនៅឆ្នាំ២០២៣[4]។ ការវិនិយោគរបស់ចិននៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជាមានច្រើន។ ក្រុមហ៊ុនចិនបានបណ្តាក់ទុនជាង១,៦ពាន់លានដុល្លារអាម៉េរិក ដើម្បីសាងសង់ទំនប់វារីអគ្គីសនីចំនួន៦នៅកម្ពុជា[5]។ នៅខែកក្កដា ឆ្នាំ២០១៨ ធនាគារនិហរណ អាហរណរបស់ចិនបានផ្តល់កម្ចីសម្បទានចំនួន២៥៩លានដុល្លារអាម៉េរិកដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ការសាងសង់ផ្លូវក្រវាត់ក្រុងជុំវិញរាជធានីភ្នំពេញចំនួន៤ខ្សែ ប្រវែង៤៧គីឡូម៉ែត្រ[6]។ ថ្មីៗនេះក្នុងខែមករា ឆ្នាំ២០១៩ ចិនបានសន្យាថា នឹងផ្តល់ជំនួយចំនួន៤ពាន់លានយ័ន ស្មើនឹង៥៨៨លានដុល្លារអាម៉េរិកដល់កម្ពុជាសម្រាប់ឆ្នាំ២០១៩ដល់ឆ្នាំ២០២១[7]។ គិតមកត្រឹមខែមេសា ឆ្នាំ២០១៩នេះ ប្រទេសចិនបានកសាងសម្រាប់ប្រទេសកម្ពុជាផ្លូវ Highways ចំនួន៣១ខ្សែ ស្ពានចំនួន៨ ដែលមានប្រវែងសរុបជាង៣ ០០០ គីឡូម៉ែត្រ កសាងស្ថានីយវារីអគ្គិសនី ស្មើនឹង៨០%នៃសមត្ថភាពផលិតថាមពលអគ្គិសនី ដែលកំពុងដំណើរការនៅកម្ពុជា[8]។

---

[2] Xi Jinping: Speech at the Opening Ceremony of the Belt and Road Forum for International Cooperation, 14 May 2017.

[3] Cambodia-China trade volume jumps to 5.8 bln USD last year: minister, in: http://www.xinhuanet.com/english/2018-06/21/c_137270877.htm. Retrieved on April 19, 2019

[4] Reuters 2019. “Cambodian leader, in Beijing, says China pledges nearly $600 million in aid”. 22 January 2019. https://www.reuters.com/article/us-cambodia-china/cambodian-leader-in-beijing-says-china-pledges-nearly-600-million-in-aid-idUSKCN1PG0CZ Retrieved on April 19, 2019

[5] Thomas Lum. *Cambodia: Background and US Relations in brief*. 11 May 2015. Congressional Research Service. Retrieved on April 19, 2019. https://www.fas.org/sgp/crs/row/R44037.pdf

[6] South China Morning Post 2018. “Cambodia says relations with China are at ‘best stage’ ever after agreeing US$259m loan to build road” 20 July 2018. https://www.scmp.com/news/china/diplomacy-defence/article/2156142/cambodia-says-relations-china-are-best-stage-ever-after. Retrieved on April 19, 2019.

[7] Reuters 2019. “Cambodian leader, in Beijing, says China pledges nearly $600 million in aid”. 22 January 2019. https://www.reuters.com/article/us-cambodia-china/cambodian-leader-in-beijing-says-china-pledges-nearly-600-million-in-aid-idUSKCN1PG0CZ. Retrieved on April 19, 2019.

[8] https://www.facebook.com/ChineseEmbassyCambodia/. Retrieved on April 22, 2019.

## ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា

សេដ្ឋកិច្ចប្រទេសកម្ពុជាមានមានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងទសវត្សរ៍ចុងក្រោយនេះ។ ផលិតផលក្នុងស្រុកសរុបកើនឡើងជាមធ្យម៧%ចាប់តាំងពីឆ្នាំ២០១១[9]។ ឆ្នាំ២០១៨នេះ កម្ពុជាសម្រេចបានកំណើន៧,៥% លើសឆ្នាំ២០១៧( ៧% )។ ផលិតផលក្នុងស្រុកសរុប( GDP)តាមថ្លៃបច្ចុប្បន្នមានចំនួនប្រមាណ៨៩ទ្រីលានរៀល( ២២ប៊ីលានដុល្លារអាមេរិក ) ធ្វើឱ្យចំណូលសម្រាប់ប្រជាជនម្នាក់ៗកើនដល់១៤៣៤ដុល្លារអាមេរិក[10]។ កំណើនខ្ពស់នេះបានមកដោយសារភាពរឹងមាំនៃវិស័យកាត់ដេរ សំណង់ និងទេសចរណ៍ ស្របពេលដែលពិពិធកម្មផលិតផលនិងគោលដៅនាំចេញត្រូវបានលើកកម្ពស់។ ទន្ទឹមគ្នានឹងនេះដែរ ខឿនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានផ្លាស់ប្តូរបន្តិចម្តងៗពីការពឹងផ្អែកវិស័យកសិកម្ម ទៅពឹងផ្អែកវិស័យឧស្សាហកម្ម ( សូមមើលតារាងទី១ )។

ផលិតផលស្រូវប្រចាំឆ្នាំ២០១៨មានចំនួន១០ ៦៧២ពាន់តោន មានការកើនឡើង៣%ធៀបនឹងឆ្នាំ២០១៧ដែលមានទំហំ១០ ៣៩៨ពាន់តោន។ ការកើនឡើងនេះបណ្តាលមកពីការកើនឡើងផ្ទៃដីដាំដុះនិងទិន្នផលដែលកើនពី៣,២៩៨តោន/ហិកតាឆ្នាំ២០១៧ទៅ៣,៣៤២តោន/ហិកតាឆ្នាំ២០១៨។ ក្នុងឆ្នាំ២០១៨ ផលិតផលកៅស៊ូមានចំនួន២២០,១ពាន់តោន កើនឡើង១៣,៩%ធៀបនឹងឆ្នាំ២០១៧។ ផលិត
កម្មនេសាទឆ្នាំ២០១៨មានចំនួន ៩១០,២ ពាន់តោន មានការកើនឡើង៦%ធៀបនឹងឆ្នាំ២០១៧[11]។

**តារាងទី១៖ ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចពីការពឹងផ្អែកកសិកម្មទៅពឹងផ្អែកឧស្សាហកម្ម**




12

ចុះ១៦%ធៀបនឹងឆ្នាំ២០១៧ តែរោងចក្រថ្មីដែលបានចុះបញ្ជីមានការកើនឡើងពី១៥០ក្នុងឆ្នាំ២០១៧ទៅ១៧៨ក្នុងឆ្នាំ២០១៨។

---

[9] http://www.nis.gov.kh/nis/NA/NA2016_Tab.htm ដកស្រង់ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៨

[10] មានកំណើនទ្វេដងក្នុងរយៈពេលមួយទសវត្សចុងក្រោយ។

[11] ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌៖ ព្រឹត្តិបត្រព័ត៌មានលេខ១ ត្រីមាសទី១ ឆ្នាំ២០១៩ ទំព័រ១២

ការនាំចូលក្នុងឆ្នាំ២០១៨មានចំនួន ១៦ ៩៥៣,៩ លានដុល្លារអាម៉េរិក កើនឡើង២៣%បើធៀបនឹងឆ្នាំ២០១៧ ចំណែកឯការនាំចេញវិញមាន ១២ ៨៨៣,២ ដុល្លារអាម៉េរិក កើនឡើង១២%បើធៀបនឹងឆ្នាំ២០១៧[12]។

ប្រៀបធៀបនឹងឆ្នាំ២០១៦ ឆ្នាំ២០១៧មានកំណើនភ្ញៀវទេសចរអន្តរជាតិ១២% ខ្ពស់ជាង២ដងនៃកំណើនមធ្យមក្នុងរយៈពេល៣ឆ្នាំចុងក្រោយ(៦%)។ ចំណូលពីវិស័យទេសចរណ៍បានកើនឡើងដល់ ៣,៨ប៊ីលានដុល្លារអាម៉េរិក មានកំណើន១៧%ក្នុងឆ្នាំ២០១៧ ប្រៀបធៀបនឹងឆ្នាំ២០១៦កន្លងទៅ។ កំណើនខ្ពស់នៃភ្ញៀវទេសចរចិនបានឈានដល់លំដាប់ថ្នាក់លេខ១(២២%នៃភ្ញៀវទេសចរអន្តរជាតិសរុប) ដោយសារមានការអំណោយផលពីការអភិវឌ្ឍគោលដៅទេសចរណ៍នៅតំបន់ឆ្នេរ កំណើនពាណិជ្ជកម្មនិងការវិនិយោគចិន ជាពិសេសលើវិស័យសំណង់និងអចលនទ្រព្យ និងបន្ទាប់ពីមានការតភ្ជាប់ជើងហោះហើរត្រង់រវាងកម្ពុជានឹងទីក្រុងធំៗរបស់ប្រទេសចិន។ ឆ្នាំ២០១៨នេះ កម្ពុជាទទួលបានភ្ញៀវទេសចរ ៦ ២០១ ០៧៧នាក់[13]។

**សំណូមពរ**

តាមរយៈគំនិតផ្តួចផ្តើមផ្លូវនិងខ្សែក្រវាត់នេះយើងបានឃើញថា សេដ្ឋកិច្ចប្រទេសកម្ពុជាមានការរីកចម្រើនជាងពេលណាៗទាំងអស់ ដែលមិនធ្លាប់មានពីមុនមក។ ទោះណាក៏ដោយ ក្នុងការអនុវត្តន៍ជាក់ស្តែងតែងមានការខ្វះចន្លោះបន្តិចបន្តួចជាមិនខាន។ ខាងក្រោមនេះជាសំណូមពរមួយចំនួនដែលលើកឡើងសម្រាប់ធ្វើឱ្យប្រសើរឡើងនូវការអនុវត្តន៍គំនិតផ្តួចផ្តើមផ្លូវនិងខ្សែក្រវាត់នៅប្រទេសកម្ពុជា៖

**តម្លាភាព**

កន្លងមកការអនុវត្តរបស់បុគ្គលិកគម្រោងខ្លះ ជាពិសេសគឺការប្រើប្រាស់ថវិកាមិនសូវចំគោលដៅរបស់គម្រោង ជាហេតុនាំឱ្យលទ្ធផលរបស់គម្រោងមួយចំនួនតូចមិនសូវមានគុណភាព។ ប្រការនេះធ្វើឱ្យប្រជាជនកម្ពុជាមួយចំនួនធ្វើការរិះគន់ថា លទ្ធផលគម្រោងរបស់ចិនមិនសូវល្អ។ ជាក់ស្តែងសមត្ថភាពបច្ចេកទេសរបស់អ្នកជំនាញចិនខ្ពស់ តែបញ្ហាដែលត្រង់ចំណុចខ្លះមានគុណភាពមិនល្អនោះ គឺដោយសារការប្រើប្រាស់ថវិកាមិនចំគោលដៅរបស់គម្រោង។ ម្ល៉ោះហើយការអនុវត្តគម្រោងខ្លះមានការយឺតយ៉ាវព្រោះទាមទារឱ្យមានការពិភាក្សាគ្នាចុះឡើងច្រើនដង រហូតឈានដល់ការប៉ះប៉ូវឡើងវិញ អាចអស់ថវិកាសរុបជាក់ស្តែងច្រើនជាងមុន។ ដូចនេះបើមានតម្លាភាពក្នុងការប្រើប្រាស់ថវិកា យើងអាចចំណេញពេលច្រើន និងទទួលបានការសាទរពីប្រជាជនកម្ពុជាកាន់តែច្រើនជាងមុន។

---

[12] ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌៖ ព្រឹត្តិបត្រព័ត៌មានលេខ១ ត្រីមាសទី១ ឆ្នាំ២០១៩ ទំព័រ១៤

[13] ក្រសួងទេសចរណ៍៖ របាយការណ៍សមិទ្ធិផលការងារប្រចាំឆ្នាំ២០១៨ ភ្នំពេញ ឆ្នាំ២០១៩

**ប្រើប្រាស់កម្លាំងពលកម្មក្នុងស្រុកឱ្យបានច្រើន**

តាមធម្មតាក្នុងការអនុវត្តគម្រោងនីមួយៗមានពេលកំណត់។ អ្នកគ្រប់គ្រងគម្រោងតែងចង់បានកម្លាំងពលកម្មដែលមានជំនាញ តស៊ូ អត់ធ្មត់នឹងការងារ។ សម្រាប់ពលករកម្ពុជាភាគច្រើនមិនទាន់មានបទពិសោធន៍ធ្វើការក្នុងគម្រោងដែលមានពេលកំណត់ ជាពិសេសជាមួយជនជាតិចិននៅក្នុងគំនិតផ្តួចផ្តើមផ្លូវនិងខ្សែក្រវាត់ ម្ល៉ោះហើយទាមទារឱ្យមានរយៈពេលមួយសម្រាប់ហ្វឹកហាត់។ ការហ្វឹកហាត់អាចធ្វើឡើងមុនពេលអនុវត្តគម្រោង ឬក៏ជាការហ្វឹកហាត់ក្នុងការងារនោះតែម្តង ហ្វឹកហាត់ទាំងជំនាញ ទាំងរបៀបរបបការងារ។ ធ្វើបែបនេះពលករកម្ពុជាអាចចូលរួមចំណែកបានកាន់តែច្រើនជាងជាងមុនក្នុងគំនិតផ្តួចផ្តើមផ្លូវនិងខ្សែក្រវាត់។

**ប្រើប្រាស់ក្រុមហ៊ុននិងវត្ថុធាតុដើមក្នុងស្រុក**

លទ្ធផលរបស់គម្រោងដែលអនុវត្តក្នុងក្របខណ្ឌគំនិតផ្តួចផ្តើមផ្លូវនិងខ្សែក្រវាត់ ពិតជាបានចូលរួមចំណែកធ្វើឱ្យប្រសើរឡើងនូវជីវភាពរបស់ប្រជាជនកម្ពុជាជាទូទៅ។ បើសិនជាគម្រោងនោះ អាចប្រើប្រាស់ក្រុមហ៊ុនក្នុងស្រុក ឧទាហរណ៍ជាអ្នកផ្គត់ផ្គង់វត្ថុធាតុដើម នោះប្រជាជនកម្ពុជានឹងទទួលបានផលប្រយោជន៍ដោយផ្ទាល់កាន់តែច្រើនទៀត។

**បង្កើនតម្លៃបន្ថែម**

រាជរដ្ឋាភិបាលកម្ពុជាតែងតែស្វាគមន៍គ្រប់អ្នកវិនិយោគិនបរទេសទាំងអស់ដែលមានបំណងចង់មកបណ្តាក់ទុននិងគោរពច្បាប់នៅកម្ពុជា ជាពិសេសដើម្បីស្រូបយកកម្លាំងពលកម្ម។ តាមរយៈនេះ នៅក្នុងផលិតកម្មមួយចំនួននៅកម្ពុជា ហាក់ដូចជាពុំសូវមានការបង្កើតតម្លៃបន្ថែមប៉ុន្មានទេ។ ការចូលរួមចំណែក ជាក់ស្តែងនៅក្នុងផលិតកម្មមានតែកម្លាំងពលកម្មដែលមិនសូវមានជំនាញ ក្នុងករណីខ្លះទៀតខ្សែសង្វាក់ផលិតកម្មខ្លះក៏មិនទាន់បានរៀបចំឬផ្តល់ឱកាសឱ្យមានការបង្កើតតម្លៃបន្ថែមដែរ។ ក្នុងការជ្រើសរើសវិស័យសម្រាប់ការវិនិយោគក្នុងក្របខណ្ឌគំនិតផ្តួចផ្តើមផ្លូវនិងខ្សែក្រវាត់ គួរជ្រើសរើសយកវិស័យឬខ្សែសង្វក់ផលិតកម្មបែបណាដែលកម្ពុជាមានឱកាសបង្កើតតម្លៃបន្ថែមផងដែរ។

**ជំរុញការនាំចេញដោយផ្ទាល់**

គិតមកត្រឹមពេលបច្ចុប្បន្ន ជញ្ជីងពាណិជ្ជកម្មកម្ពុជា-ចិនមិនទាន់មានតុល្យភាពទេ កម្ពុជានាំចូលពីចិនច្រើន។ មានមូលហេតុជាច្រើនដែលនាំឱ្យចេញជាលទ្ធផលបែបនេះ ដូចស្ថានទូតចិននៅកម្ពុជាបានលើកឡើងនាពេលកន្លងមក។ បន្ថែមលើនេះទៀតមានផលិតផលខ្លះ ដូចជាផ្លែស្វាយ និងកសិផលផ្សេងទៀត ដែលប្រជាជនកម្ពុជាបានលក់ទៅឱ្យប្រទេសវៀតណាម ហើយប្រទេសវៀតណាមលក់បន្តទៅចិន។ ការធ្វើបែបនេះអាចនាំឱ្យផលិតផលកម្ពុជាមួយចំនួនមានថ្លៃដើមទាបនៅប្រទេសចិន រីឯកម្ពុជាក៏មានលទ្ធភាពបង្កើនការនាំចេញដោយផ្ទាល់ទៅប្រទេសចិនដែរ។

# ឯកសារបណ្ណាល័យសាស្ត្រ


1- ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌៖ ព្រឹត្តិបត្រព័ត៌មានលេខ១ ត្រីមាសទី១ ឆ្នាំ២០១៩

2- ក្រសួងទេសចរណ៍៖ របាយការណ៍សមិទ្ធិផលការងារប្រចាំឆ្នាំ២០១៨ ភ្នំពេញ ឆ្នាំ២០១៩

3- វង្សី វិស្សុតៈ កម្ពុជា កាលានុវត្តភាពនិងការប្រឈមក្នុងដំណើរការកសាងជាតិ ឆ្នាំ២០១៨

4- Cambodia-China trade volume jumps to 5.8 bln USD last year: minister, in: http://www.xinhuanet.com/english/2018-06/21/c_137270877.htm.

5- Reuters 2019. “Cambodian leader, in Beijing, says China pledges nearly $600 million in aid”. 22 January 2019. In: https://www.reuters.com/article/us-cambodia-china/cambodian-leader-in-beijing-says-china-pledges-nearly- 600-million-in-aid-idUSKCN1PG0CZ

6- South China Morning Post 2018. “Cambodia says relations with China are at ‘best stage’ ever after agreeing US$259m loan to build road” 20 July 2018. In: https://www.scmp.com/news/china/diplomacy defence/article/2156142/cambodia-says-relations-china-are-best-stage-ever-after.

7- Thomas Lum. *Cambodia: Background and US Relations in brief*. 11 May 2015. Congressional Research Service. In: https://www.fas.org/sgp/crs/row/R44037.pdf

8- Xi Jinping: Speech at the Opening Ceremony of the Belt and Road Forum for International Cooperation, 14 May 2017.

9- https://www.facebook.com/ChineseEmbassyCambodia

10- http://www.nis.gov.kh/nis/NA/NA2016_Tab.htm

11- https://km.wikipedia.org/wiki/កំណត់ហេតុ ជីវ តាក្វាន់